**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលខជ្ជាជីវៈ**
**លេខ :** ២៧៧/២០ **ក.ប**/ប.ក.ខ.ល

# ប្រកាស
## ស្តីពី
## ការប្រើប្រាស់កម្មករនិយោជិតបរទេសជាលក្ខណៈពិសេស

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ម្ចាស់ ឬនាយកសហគ្រាសទាំងឡាយ ដែលស្ថិតនៅក្រោមវិសាលភាពមាត្រា១នៃច្បាប់ស្តីពីការងារ ដែលមានតម្រូវការប្រើប្រាស់កម្លាំងពលកម្ម ប៉ុន្តែមិនអាចស្វែងរក ឬមិនមានកម្មករនិយោជិតខ្មែរគ្រប់គ្រាន់សម្រាប់ចូលបម្រើការងារនៅកន្លែងធ្វើការណាមួយ ឬប្រភេទការងារណាមួយ ឬតាមវេនការងារណាមួយ នោះអាចស្នើសុំប្រើប្រាស់កម្មករនិយោជិតបរទេសជាលក្ខណៈពិសេស លើសពី ១០% នៃចំនួនសរុបកម្មករនិយោជិតខ្មែរ។

**ប្រការ២ .-**

ដើម្បីប្រើប្រាស់កម្មករនិយោជិតបរទេសជាលក្ខណៈពិសេសនេះ ម្ចាស់ ឬនាយកសហគ្រាស ត្រូវ៖

១. ធ្វើលិខិតសុំការអនុញ្ញាតប្រើប្រាស់កម្មករនិយោជិតបរទេស ពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សររបស់ជនបរទេសនីមួយៗ។


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

២. បំពេញបែបបទស្នើសុំបណ្ណ/សៀវភៅការងារជនបរទេស តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (FWCMS) តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh ។

៣. បង់អាករសេវាការផ្តល់បណ្ណ/សៀវភៅការងារជនបរទេស ដូចមានចែងក្នុងប្រកាសអន្តរក្រសួង រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤. មានទិដ្ឋាការ/បណ្ណស្នាក់នៅស្របច្បាប់។

**ប្រការ៣ .–**

ម្ចាស់ ឬនាយកសហគ្រាស ឬជនទាំងឡាយ ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវផ្តន្ទាទោស តាមជំពូកទី១៦នៃច្បាប់ស្តីពីការងារ។

**ប្រការ៤ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥ .–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ